**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**លេខៈ** ៦៥៦ សរ.ជណ

ថ្ងៃ សុក្រ ១០កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**

- **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច**

**កម្មវត្ថុ៖** ករណីការស្នើសុំពិនិត្យនិងសម្រេចលើគោលការណ៍គន្លឹះ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់រាជរដ្ឋាភិបាល។

**យោង ៖** - លិខិតលេខ៤៣៣៧ សហវ.ល.ស.អ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលយល់ព្រមជាគោលការណ៍គន្លឹះចំនួន៥ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់រាជរដ្ឋាភិបាល និងរៀបចំគោលការណ៍គន្លឹះទាំងនេះ ជាជំពូករួមមួយ កំណត់ពីបទប្បញ្ញត្តិទូទៅនៃការរៀបចំប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់រាជរដ្ឋាភិបាលនៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ច (ឬសេចក្ដីព្រាងច្បាប់ស្ដីពីប្រព័ន្ធសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចរបស់រាជរដ្ឋាភិបាល) ឱ្យបានទាន់យ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០២៤នេះ ដូចខាងក្រោម៖

១. ការកំណត់អង្គភាពត្រួតពិនិត្យរបស់ក្រសួង ស្ថាប័ន

ក. ការកំណត់អង្គភាពត្រួតពិនិត្យផ្ទៃក្នុង

- ការត្រួតពិនិត្យផ្ទៃក្នុងនៅអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នសាមី លើគ្រប់ផ្នែកទាំងអស់ជាអាទិ៍ រដ្ឋបាល បុគ្គលិក គណនេយ្យ ហិរញ្ញវត្ថុ បច្ចេកវិទ្យាព័ត៌មាន និងប្រតិបត្តិការនានា ត្រូវប្រគល់ជូនអង្គភាពសវនកម្មផ្ទៃក្នុងតែមួយគត់ក្នុងនាមជាសេនាធិការនិងស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់

ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (តទៅទៀតហៅកាត់ថារដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន)។ ក្នុងករណីដែលអង្គភាពសវនកម្មផ្ទៃក្នុង ពិនិត្យឃើញភាពមិនប្រក្រតីនានា ឬសង្ស័យថាអាចមានហានិភ័យ រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី ត្រូវចាត់វិធានការភ្លាមដើម្បីកែលម្អភាពមិនប្រក្រតីនិងទប់ស្កាត់នូវហានិភ័យទាំងនោះ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី អាចស្នើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចាត់មន្ត្រីចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុសាធារណៈ ឬអាចស្នើមកក្រសួងមុខងារសាធារណៈ ដើម្បីចាត់មន្ត្រីចុះធ្វើអធិការកិច្ចមុខងារសាធារណៈ។ អង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន ត្រូវចម្លងរបាយការណ៍សវនកម្មប្រចាំឆ្នាំជូនទៅក្រសួងអធិការកិច្ច, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងមុខងារសាធារណៈ និងអាជ្ញាធរសវនកម្មជាតិ។

ខ. មុខងារអធិការកិច្ចជំនាញរបស់ក្រសួង ស្ថាប័ន

- ក្រសួងដែលអគ្គាធិការដ្ឋាន/អធិការដ្ឋាន មានសមត្ថកិច្ចធ្វើអធិការកិច្ចនៅអង្គភាពខាងក្រៅ តាមវិស័យជំនាញដែលក្រសួង ឬស្ថាប័នសាមីទទួលបន្ទុកដែលច្បាប់បានកំណត់ ត្រូវបន្តអនុវត្តភារកិច្ចរបស់ខ្លួនអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

- ក្រសួងដែលអង្គភាពជំនាញផ្សេងទៀតក្រៅពីអគ្គាធិការដ្ឋាន/អធិការដ្ឋាន មានសមត្ថកិច្ចធ្វើអធិការកិច្ចនៅអង្គភាពខាងក្រៅ តាមវិស័យជំនាញដែលក្រសួង ឬស្ថាប័នសាមីទទួលបន្ទុកដែលច្បាប់បានកំណត់ ត្រូវបន្តអនុវត្តភារកិច្ចរបស់ខ្លួន អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

- ក្រសួង ឬស្ថាប័នដែលមានអង្គភាពអធិការកិច្ចវិស័យជំនាញច្រើនដែលច្បាប់បានកំណត់ និងត្រូវចុះធ្វើអធិការកិច្ចដែលមានកម្មវត្ថុផ្សេងគ្នា គោលដៅផ្សេងគ្នា អាចចុះធ្វើអធិការកិច្ចតាមសមត្ថកិច្ចរៀងៗខ្លួនអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយផ្អែកលើអភិក្រមគ្រប់គ្រងហានិភ័យ ករណីសង្ស័យ និងករណីមានបណ្តឹង។ លើកលែងតែករណីមានការសង្ស័យ និងករណីមានបណ្តឹងដែលត្រូវមានលក្ខខណ្ឌវិនិច្ឆ័យ និងវិធានកំណត់ច្បាស់លាស់, ការធ្វើអធិការកិច្ចតាមអភិក្រមគ្រប់គ្រងហានិភ័យ ជាគោលការណ៍ ត្រូវកំណត់ឱ្យមានគម្លាតពេលយ៉ាងហោចបីឆ្នាំ។ ដោយឡែក ការចុះធ្វើអធិការកិច្ចនៅគោលដៅតែមួយ និងក្នុងការិយបរិច្ឆេទតែមួយ ទោះបីមានកម្មវត្ថុផ្សេងគ្នា ត្រូវមានកិច្ចសហការរវាងអង្គភាពពាក់ព័ន្ធរបស់ក្រសួង ឬស្ថាប័នសាមី ដើម្បីចុះទៅរួមគ្នាតែមួយលើក ដែលត្រូវដឹកនាំដោយថ្នាក់ដឹកនាំរបស់ក្រសួង ឬស្ថាប័នសាមី។

- គ្រប់ក្រសួង ស្ថាប័ន ត្រូវបានហាមដាច់ខាតការបង្កើតឱ្យមានការត្រួតពិនិត្យផ្សេងទៀត ដែលពុំមានកំណត់នៅក្នុងច្បាប់ និងត្រូវចម្លងរបាយការណ៍អធិការកិច្ចជំនាញតាមវិស័យរបស់ខ្លួនជូនទៅក្រសួងអធិការកិច្ច។

គ. សមាហរណកម្មភារកិច្ចរបស់អគ្គាធិការដ្ឋាន

ក្រសួង ស្ថាប័នដែលអគ្គាធិការដ្ឋាន/អធិការដ្ឋានពុំមានសមត្ថកិច្ច ធ្វើអធិការកិច្ចតាមវិស័យជំនាញរបស់ក្រសួង ឬស្ថាប័នសាមីទទួលបន្ទុក នៅអង្គភាពខាងក្រៅ, ក្រសួង ស្ថាប័ននោះត្រូវធ្វើសមាហរណកម្មអគ្គាធិការដ្ឋាន/អធិការដ្ឋាន បញ្ចូលគ្នាជាមួយអង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន។

២. មុខងារអធិការកិច្ចរបស់ក្រសួងអធិការកិច្ច

ក្រសួងអធិការកិច្ចគឺជាសេនាធិការរបស់រាជរដ្ឋាភិបាលលើវិស័យអធិការកិច្ច ដែលមានសមត្ថកិច្ចចុះធ្វើអធិការកិច្ចលើក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ត្រូវគោរពខ្ជាប់ខ្ជួនតាមអភិក្រម គោលការណ៍

និងវិធានលម្អិតដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ១៦៨អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច រួមមានជាអាទិ៍៖

- តាមបណ្តឹងតវ៉ា និងបណ្តឹងបរិហារពីនីតិបុគ្គល រូបវន្តបុគ្គល និងគ្រប់មជ្ឈដ្ឋាន
- តាមបណ្តឹងរបស់ស្ថាប័នវេងអធិការកិច្ចលើលទ្ធផលអធិការកិច្ចរបស់ក្រសួង ស្ថាប័ន
- ផ្អែកលើហានិភ័យ បណ្តឹងតវ៉ា ឬភាពចាំបាច់ក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន ឬរបាយការណ៍ពាក់ព័ន្ធ
- តាមសំណើរបស់សាមីក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ករណីមានភាពមិនប្រក្រតីលើរបាយការណ៍លទ្ធផលអធិការកិច្ច
- ដើម្បីតាមដាននូវរាល់វិធានការដែលអធិការកិច្ចបានដាក់ចេញដល់ស្ថាប័នវេងអធិការកិច្ច និង
- តាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

ចំពោះអធិការកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យលេខ ១៦៨អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច។

ចំពោះអធិការកិច្ចពាក់ព័ន្ធមុខងារសាធារណៈ ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៨ នៃអនុក្រឹត្យលេខ ១៦៨អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច។

៣. មុខងារអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ការធ្វើអធិការកិច្ចហិរញ្ញវត្ថុសាធារណៈជាមុខងារក្រោមសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្របតាមនិយាមស្ថាប័នជំនាញពិសេស នៃការគ្រប់គ្រងប្រតិបត្តិការចំណូល និងចំណាយរបស់រដ្ឋ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការបច្ចេកទេសតែមួយរបស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុដោយផ្អែកលើហានិភ័យ ករណីសង្ស័យ និងបណ្តឹងអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ ម្យ៉ាងទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏មានសមត្ថកិច្ចត្រួតពិនិត្យផ្សេងទៀត ដែលបានកំណត់នៅក្នុងច្បាប់ពាក់ព័ន្ធវិស័យហិរញ្ញវត្ថុសាធារណៈផងដែរ។

៤. មុខងារអធិការកិច្ចរបស់ក្រសួងមុខងារសាធារណៈ

ការធ្វើអធិការកិច្ចមុខងារសាធារណៈជាមុខងារក្រោមសមត្ថកិច្ចរបស់ក្រសួងមុខងារសាធារណៈ ស្របតាមនិយាមស្ថាប័នជំនាញពិសេសនៃការគ្រប់គ្រងនិងអភិវឌ្ឍមុខងារសាធារណៈ ជាពិសេសកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ ក្រសួងមុខងារសាធារណៈជាសេនាធិការបច្ចេកទេសតែមួយរបស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការអធិការកិច្ចលើការងារមុខងារសាធារណៈ អនុលោមអនុក្រឹត្យលេខ ១៦៨អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដូចមានគូសរំលេចខាងលើ។

### ៥. ការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវសម្របសម្រួលធ្វើការពិនិត្យពិភាក្សាជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីកាត់បន្ថយ និងចៀសវាងការធ្វើសវនកម្មស្ទួនគ្នា ដោយរក្សានូវឯករាជ្យភាពរបស់អាជ្ញាធរសវនកម្មជាតិដែលកំណត់ដោយច្បាប់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការប្រចាំការ

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**
- គ្រប់ក្រសួងស្ថាប័ន
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ